# ការអនុវត្តន៍ល្អ
## កន្លែងសំអាតស្នាមប្រឡាក់

**រោងចក្រ កាន់តែប្រសើរ** នៅកម្ពុជា

ការសំអាតស្នាមប្រឡាក់ មានភាពចាំបាច់ណាស់សំរាប់ផលិតកម្មវាយនភ័ណ្ឌ ។ ប៉ុន្តែសាធាតុគីមីមួយចំនួនដែលត្រូវបានយកមកប្រើប្រាស់ អាចបង្ករអោយមានគ្រោះថ្នាក់ ។ ចំណុចដែលសំខាន់បំផុតនោះ ត្រូវការពារអ្នកដែលធ្វើការនៅក្នុងឬក៏នៅជិតកន្លែងសំអាតស្នាមប្រឡាក់ ពីផលប៉ះពាល់នៃសារធាតុគីមី ដូចជាក្លិនរបស់សារធាតុគីមីជាដើម ។ ជាពិសេស សារធាតុគីមីដែលគេនិយមប្រើដើម្បីសំអាតស្នាមប្រឡាក់នោះគឺ *ទ្រីក្លូរ៉ូអេទីឡែន* ដែលជាសារធាតុពុលហើយត្រូវប្រុងប្រយ័ត្នជាពិសេស ។ *ទ្រីក្លូរ៉ូអេទីឡែន* អាចបង្ករអោយមានគ្រោះថ្នាក់ ប្រសិនបើវាចូលតាមការដកដង្ហើម ឬប៉ះជាមួយនឹងស្បែក ។

### *ការអនុវត្តន៍ល្អសំរាប់កន្លែងសំអាតស្នាមប្រឡាក់*

ប្រើប្រាស់បន្ទប់ពិសេសមួយ នៅដាច់ដោយឡែកសំរាប់ជាកន្លែងសំអាតស្នាមប្រឡាក់ (រូបភាពទី១) ។

បំពាក់កង្ហារបឺតខ្យល់ នៅក្នុងកន្លែងសំអាតស្នាមប្រឡាក់ ដើម្បីធានាយ៉ាងណាអោយខ្យល់ល្អចូលទៅកាន់កម្មករ រីឯក្លិនគីមីហើរចេញពីកម្មករ ។ **ប្រយ័ត្ន:** *កង្ហារ មិនត្រូវបក់ចំមុខកម្មករ ឬបក់ដែលធ្វើអោយកម្មករស្រូបយកខ្យល់សារធាតុគីមីតាមការដកដង្ហើមឡើយ* (រូបភាពទី២) ។

ប្រើប្រាស់ទឹក និងសាប៊ូ សំរាប់ការសំអាតស្នាមប្រឡាក់ ជំនួសអោយសារធាតុគីមី ប្រសិនបើអាចធ្វើទៅបាន ។

ផ្តល់សំភារៈការពារខ្លួន (PPE) ដូចជា ម៉ាស់ការពារ អាវអៀម ស្រោមដៃ និងវ៉ែនតាសុវត្ថិភាពអោយកម្មករ ។ **ប្រយ័ត្ន:** *មិនត្រូវប្រើម៉ាស់ការពារធូលីទេ ព្រោះវាអាចស្រូបសារធាតុគីមីជាប់នៅលើមុខកម្មករ* (រូបភាពទី៣) ។

ដាក់បង្ហាញសន្លឹកទិន្នន័យពតិមានស្តីពីសុវត្ថិភាពគីមី (MSDSs) នៅទីកន្លែងដែលកម្មករទាំងអស់អាចមើលឃើញ ។

ធានាថាកម្មករអាន និងយល់ដឹងពីសន្លឹកទិន្នន័យពតិមានស្តីពីសុវត្ថិភាពគីមី (MSDSs) ដែលអាចអោយពួកគេយល់ពីគ្រោះថ្នាក់នៃសារធាតុគីមី ដែលគេកំពុងប្រើប្រាស់ (រូបភាពទី៤) ។

ធានាថាកម្មករ និងបុគ្គលិកពេទ្យដឹងពីអ្វីដែលត្រូវធ្វើ ក្នុងករណីដែលមានសារធាតុគីមីដែលគ្រោះថ្នាក់បានកំពប់ ឬពេលដែលកម្មករណាម្នាក់រងរបួស ។

ធានាថាកម្មករយល់ដឹងពីរបៀបទុកដាក់សារធាតុគីមីបានយ៉ាងត្រឹមត្រូវ ។


រូបភាពទី១


រូបភាពទី២


រូបភាពទី៣


រូបភាពទី៤

### អត្ថប្រយោជន៍:

- ✓ ការពារកម្មករមិនអោយទទួលរងសារធាតុគីមីសំអាតស្នាមប្រឡាក់ដោយផ្ទាល់ និងដោយប្រយោល
- ✓ ការពារកម្មករមិនអោយមានជំងឺដូចជា ជំងឺរយៈពេលខ្លី និងជំងឺរយៈពេលវែង
- ✓ សន្សំសំចៃការចំណាយលើថ្លៃព្យាបាលជំងឺ
- ✓ កាត់បន្ថយចំនួនអវត្តមានដោយសារមានជំងឺ
- ✓ បរិយាកាសការងារកាន់តែមានសុវត្ថិភាព

### តាមរបៀបណា:

- ✓ រៀបចំបន្ទប់សំអាតស្នាមប្រឡាក់ ដាច់ដោយឡែកពីគេក្នុងរោងចក្រ
- ✓ បិទសេចក្តីណែនាំនេះ និង MSDSs នៅលើជញ្ជាំងបន្ទប់សំអាតស្នាមប្រឡាក់
- ✓ សំភារៈការពារខ្លួន ដូចជាស្រោមដៃ និងអាវអៀម អាចរកបាននៅក្នុងទីផ្សារក្នុងស្រុក
- ✓ វ៉ែនតាសុវត្ថិភាព និងម៉ាស់មានតម្រងខ្យល់ដកដង្ហើម (សំរាប់ការពារឧស្ម័ន និងសាំងក្រអូប) អាចរកបាននៅតាមទីផ្សារពាណិជ្ជកម្ម

### តំលៃ:

**$**

- **$** តំលៃទាប
- **$$** តំលៃមធ្យម
- **$$$** តំលៃខ្ពស់

អង្គការ ពលកម្ម អន្តរជាតិ

ប្រសិនបើលោកអ្នកមានសំនួរ សូមទាក់ទងមកអង្គការពលកម្មអន្តរជាតិតាមរយៈអ៊ីម៉េល betterfactories@ilo.org